ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខៈ......១១៧........ កប/ប្រ.ក

# ប្រកាស
## ស្តីពី
## ការតែងតាំងគណៈកម្មការវេជ្ជសាស្ត្រ នៃបេឡាជាតិរបបសន្តិសុខសង្គម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសន្តិសុខសង្គម សំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- ប្រកាសរួមលេខ ០៨៨/០៩ កប /ប្រក ចុះថៃ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មការវេជ្ជសាស្ត្រ នៃបេឡាជាតិរបបសន្តិសុខសង្គម
- យោងលិខិតលេខ ០២៨ ពបស/ផពស ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ របស់ក្រសួងសុខាភិបាល
- យោងាតាមការចាំបាច់

## សម្រេច

**ប្រការ១.-** ត្រូវបានតែងតាំងមន្ត្រីចំនួន ០៥ រូប នៅក្នុងគណៈកម្មការវេជ្ជសាស្ត្រ នៃបេឡាជាតិរបបសន្តិសុខសង្គម ដូចមានរាយនាមនៅខាងក្រោម:

| | | |
|---|---|---|
| ១- លោកវេជ្ជ. **ប៉ុក វណ្ណថាត** | អនុប្រធាននាយកដ្ឋានពេទ្យការងារ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- លោកវេជ្ជ. **សុខ ស្រ៊ុន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ<br>នៃក្រសួងសុខាភិបាល | អនុប្រធាន |
| ៣- លោកវេជ្ជ. **ភុល ហៀ** | អនុប្រធាននាយកដ្ឋានការពារសុខភាព<br>នៃក្រសួងសុខាភិបាល | សមាជិក |
| ៤- លោកវេជ្ជ. **ហាន់ នព្វគុណ** | ប្រធានការិយាល័យ នៅនាយកដ្ឋានពេទ្យការងារ<br>នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកបំរុង |
| ៥- លោកវេជ្ជ. **សុខ ម៉ូ** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ<br>នៃក្រសួងសុខាភិបាល | សមាជិកបំរុង |

**ប្រការ២.-** សមាសភាពគណៈកម្មការវេជ្ជសាស្ត្រ នៃបេឡាជាតិរបបសន្តិសុខសង្គម អាចធ្វើការកែសម្រួលបាននៅពេលមានតម្រូវការចាំបាច់។

**ប្រការ៣.-** ខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកការងារ អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការ នាយកបេឡាជាតិរបបសន្តិសុខសង្គម សាមីខ្លួនដែលមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ[illegible] ឆ្នាំ២០០៩

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ៣ " ដើម្បីអនុវត្ត "
- កាលប្បវត្តិ និងឯកសារ